**សកម្មភាព** ៖ **ល្បែងអានសៀវភៅ**

**ភាសាខ្មែរ**

ការស្តាប់ (ស្តាប់គេនិយាយ និងមានសម្ថភាពស្តាប់ដោយធ្វើតាមការណែនាំងាយៗ)

ប្រើពាក្យសម្តីកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង (ទំនាក់ទំនងដោយប្រើពាក្យសម្តី)

**គោលបំណង** ៖

**(ភាសាខ្មែរ)** ប្រាប់បានខ្លះៗពីដំណើររឿងតាមរយៈរូបភាពដែលបានបង្ហាញ។

ប្រាប់ឡើងវិញពីសកម្មភាពតាមដំណាក់កាល ដោយអនុវត្តតាមដំណាក់កាលណែនាំ។

ប្រាប់ចំណងជើងរឿង និងអត្ថន័យតាមរូបភាព។ និទានរឿងតាមរូបភាពស្តាប់។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង “តើអ្នកពូកែអី?” ។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សៀវភៅតើអ្នកពូកែអី?

**ការរៀបចំ** ៖ សូមអានសៀវភៅរឿងជាមុន ដើម្បីឱ្យដឹងពីខ្លឹមសារនៃសាច់រឿង។ សូមសរសេរសំណួរដែលអ្នកចង់សួរទៅកាន់ក្មេងៗ។ គំរូសំណួរអាចមានដូចជា៖

**សេចក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងអានសៀវភៅរឿង “តើអ្នកពូកែអី?” ឱ្យកូនៗស្តាប់ទាំងអស់គ្នា។
2. បង្ហាញសៀវភៅរឿង “តើអ្នកពូកែអី?” ទៅកាន់ក្មេងៗទាំងអស់គ្នា។
3. ឱ្យក្មេងៗនិយាយពាក្យថា ‹‹សៀវភៅ›។
4. បង្ហាញពីរបៀបនៃការកាន់ និងថែទាំសៀវភៅ។ ឧទាហរណ៍៖ កុំបត់សៀវភៅទៅក្រោយ កុំហែកសន្លឹកសៀវភៅឬកុំគូរវាសផ្តេសផ្តាសលើសៀវភៅ(ការគូររូបលើសៀវភៅគឺសម្រាប់តែសៀវភៅផាត់ពណ៌ ឬ សៀវភៅគូររូបប៉ុណ្ណោះ)។
5. បង្ហាញក្របសៀវភៅទៅកាន់ក្មេងៗ ហើយពន្យល់អំពីចំណងជើងរឿង ។
6. ឱ្យក្មេងៗទាំងអស់ថាតាម ចំណងជើងរឿង “តើអ្នកពូកែអី?” ។
7. អានសៀវភៅរឿងចាប់ពីទំព័រដើមរហូតដល់ចប់យឺតៗ ដោយបង្ហាញរូបភាពក្នុងទំព័រនីមួយៗ។
8. សួរក្មេងៗអំពីសំណួរដែលអ្នកបានត្រៀមទុក ។

ឧទាហរណ៍៖

- តើមករាពូកែខាងអ្វី?
- តើរតនាពូកែខាងអ្វី?
- តើលោកគ្រូសុខបាននាំពួកគាត់ទៅនៅឯណា?
- តើមានផ្លែដូងប៉ុន្មាន?

9. ចូរអនុញ្ញាតឱ្យក្មេងៗសួរសំណួរអំពីសាច់រឿង និងរូបភាព ហើយឆ្លើយសំណួររបស់ក្មេងៗ។

**បម្រែបម្រួល៖** អ្នកអាចធ្វើតាមជំហានទាំងនេះសម្រាប់សៀវភៅដែលមានរូបភាព។